ព្រឹត្តិបត្រ

# សាលារាជធានីភ្នំពេញ

## PHNOM PENH CAPITAL CITY NEWSLETTER



ឯកឧត្តម ប៉ា សុជាតិវង្ស រួមជាមួយគណៈប្រតិភូសាលារាជធានីភ្នំពេញ ជួបជាមួយទីចាត់ការបច្ចេកទេសរបស់ទីភ្នាក់ងារអភិវឌ្ឍន៍ ទីក្រុងប៉ារីស នៃប្រទេសបារាំង


(៨៥៥)២៣-៧២២-០៥៤
(៨៥៥) ២៣-៧២២-០៥៤
www.phnompenh.gov.kh
info@phnompenh.gov.kh



ឆ្នាំ២០១៥ លេខ១២ ត្រីមាសទី៣ ឆ្នាំទី២

#៦៩, មហាវិថីព្រះមុនីវង្ស, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


- ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហមុនី ថ្វាយសារអរគុណ ឯកឧត្តម ប៉ា សុជាតិវង្ស.......០៤
- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ..........................០៦
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ស្ពានជ្រោយចង្វារមិត្តភាពកម្ពុជា-ចិន...................................០៨
- កិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី២ ..........................១០
- ប្រតិភូសាលារាជធានីភ្នំពេញ ធ្វើដំណើរទស្សនកិច្ចផ្លូវការ នៅទីក្រុងប៉ារីស ប្រទេសបារាំង.......១១
- ពិធីក្រុងពាលី និងអភិសេករូបសំណាកព្រះព្រហ្មមុខបួន នៅរង្វង់មូលជ្រោយចង្វារ................១៧
- កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ..................................................១៩
- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី អាណត្តិទី២ .......................២០
- ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង...........២១
- ពិធីសម្ពោធអគារស្នាក់នៅសម្រាប់កងទ័ព និងរោងរថក្រោះរបស់បញ្ជាការដ្ឋានអង្គរក្ស ...........២៣
- សាលារាជធានីភ្នំពេញ បានបើកកិច្ចប្រជុំស្តីពី គម្រោងអភិវឌ្ឍន៍រាជធានីភ្នំពេញ...................២៤
- ថ្នាក់ដឹកនាំសាលារាជធានីភ្នំពេញ ទទួលជួបអភិបាលរងទីក្រុងគីតាគ្យូស្យូ.........................២៥
- ប្រតិភូសាលារាជធានីភ្នំពេញជួបពិភាក្សាការងារជាមួយ អនុប្រធានធនាគារពិភពលោក.........២៦
- ពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១៥-២០១៦ និងចែករង្វាន់សិស្សពូកែ រាជធានីភ្នំពេញ.....២៧
- កិច្ចប្រជុំបញ្ចៀសការកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញ ក្នុងរដូវបុណ្យទាន.......................២៨
- សិក្ខាសាលា "ការកកស្ទះចរាចរណ៍នៅកម្ពុជា ប៉ះពាល់ដល់បរិស្ថាន និងសុខុមាលភាព ".....២៩
- ផ្លូវលេខ២៧១ ចាក់អ៊ុតកៅស៊ូបានជាង៤០% លើប្រវែងសរុប ៧.៧០០ម៉ែត្រ .......................៣០


១. សកម្មភាពថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា...



២. សកម្មភាពក្រុមប្រឹក្សារាជធានីភ្នំពេញ...




៣. សកម្មភាពអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ...



៤. សកម្មភាពអភិបាល នៃគណៈអភិបាលខណ្ឌ...



៥. ចំណេះដឹង ការកម្សាន្ត និងបទវិចារណកថាផ្សេងៗ...

**ការិយាល័យនិពន្ធ**

សាលារាជធានីភ្នំពេញ #៦៩, មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៧២២ ០៥៤, ទូរសារ : (៨៥៥) ២៣ ៧២២ ០៥៤
Email: info@phnompenh.gov.kh, Website: www.phnompenh.gov.kh

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ**
**នរោត្ដម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្តម **ប៉ា សុជាតិវង្ស**
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

ឯកឧត្តម ជាទីស្រឡាញ់រាប់អាន

ខ្ញុំបានទទួលរួចហើយនូវលិខិត ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ របស់ឯកឧត្តម ដែលមានអត្ថន័យដ៏ជ្រាលជ្រៅ ថ្វាយសព្ទសាធុការពរជ័យ និងអបអរសាទរ ក្នុងឱកាសពិធីបុណ្យខួបទី១១ឆ្នាំ នៃការឡើងគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ខ្ញុំ។

ខ្ញុំសូមអរគុណដ៏ជ្រាលជ្រៅ និងសូមជូនពរ ឯកឧត្តម ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់ក្នុងរាជធានីភ្នំពេញ បានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម ទទួលនូវសេចក្ដីស្រឡាញ់រាប់អាន អំពីខ្ញុំ។

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៥

# សូមក្រាបបង្គំទូលថ្វាយព្រះពរ

ថ្វាយ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត



២៩ តុលា ២០០៤ — ១១ — ២៩ តុលា ២០១៥

## ក្នុងឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាល

## ខួប ១១ ព្រះវស្សា នៃព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិ

ក្រាបបង្គំទូលថ្វាយពី ឯកឧត្តម ប៉ា សុជាតិវង្ស និងលោកជំទាវ

និងគណៈអភិបាល ព្រមទាំងមន្ត្រីរាជការក្រោមឱវាទនៃសាលារាជធានីភ្នំពេញ



## ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ

នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ នៅសាលារាជធានីភ្នំពេញ បានរៀបចំពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ



ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង ក្នុងព្រះរាជពិធីគម្រប់ខួប៣ឆ្នាំនៃការយាងចូលទិវង្គតរបស់ព្រះអង្គ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃសាលារាជធានីភ្នំពេញយ៉ាងច្រើនកុះករ។ នៅក្នុងថ្ងៃគម្រប់ខួបទី ៣ នៃថ្ងៃដែលព្រះអង្គចូលទិវង្គត ថ្នាក់ដឹកនាំ និងមន្ត្រីសាលារាជធានីភ្នំពេញ បានក្រាបថ្វាយព្រះពរដល់ព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជាទីនឹករលឹកបំផុតពីកូនចៅ សូមទ្រង់បានយាងទៅសោយសុខនៅឋានសួគ៌ា



និងសូមកម្ពុជាទទួលបានតែសុខសន្តិភាព វិបុលភាព និងរីកចម្រើនជានិច្ចនិរន្តរ៍ ក្នុងឱកាសនៃព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ៕









ព្រះរាជកិច្ចដឹកនាំរបស់**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ក្នុងសម័យសង្គមរាស្ត្រនិយម ដែលប្រជារាស្ត្រខ្មែរបានថ្វាយព្រះនាមព្រះអង្គថាជា ព្រះបិតាឯករាជ្យជាតិ ព្រះបិតាសិក្សាធិការជាតិ ព្រះបិតាសុខាភិបាលជាតិ ព្រះបិតាកីឡាជាតិ ព្រះបិតាស្ថាបនាជាតិ សមិទ្ធផលនានាជាច្រើនត្រូវបានកសាងឡើង និងប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់សម្រាប់ប្រជារាស្ត្រ ប្រើប្រាស់នៅតាមបណ្តាខេត្ត-ក្រុងនានាជាពិសេសមានសមិទ្ធផលធំៗ ដូចជា វិមានឯករាជ្យ វិមានរដ្ឋចំការមន ចំណតអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ចំណតអាកាសយានដ្ឋានសៀមរាប ចំណតអាកាសយានដ្ឋានបៃកចាន ខេត្តបាត់ដំបង ផ្លូវជាតិលេខ៤ ភ្នំពេញ-ក្រុងព្រះសីហនុ ផ្លូវដែកក្រុងភ្នំពេញ-ក្រុងព្រះសីហនុ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សណ្ឋាគារ«ឯករាជ្យ»ក្រុងព្រះសីហនុ សាលមហោស្រពជាតិ «ព្រះសុរាម្រិត» ភ្នំពេញ សាលសន្និសីទ «ចតុមុខ» ពហុកីឡដ្ឋានជាតិអូឡាំពិកភ្នំពេញ ស្ពានព្រះមុនីវង្សទី២ ស្ពាន«សង្គមរាស្ត្រនិយម»ឆ្លងកាត់ទន្លេសាប សាកលវិទ្យាល័យ «សង្គមរាស្ត្រនិយម»ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យគរុកោសល្យ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មហាវិទ្យាល័យសិល្បៈស្ថាបនា មហាវិទ្យាល័យសិល្បៈនិងមុខរបរ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទក្សេត្រសាស្ត្រ សាកលវិទ្យាភូមិន្ទកំពង់ចាម សាកលវិទ្យាល័យភូមិន្ទបាត់ដំបង សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត រោងភាពយន្តរដ្ឋ ស្ថានីយទូរទស្សន៍ខេមរភូមិន្ទ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រោងចក្រចម្រាញ់ប្រេងកាតក្រុងព្រះសីហនុ រោងចក្រស្រាបៀរក្រុងព្រះសីហនុ




រោងចក្រ«ព្រះនរោត្តម»ដំឡើងត្រាក់ទ័រ និងរថយន្តធំក្រុងព្រះសីហនុ រោងចក្រស្ករសកំពង់ត្រាំខេត្តកំពង់ស្ពឺ រោងចក្រវាយនភ័ណ្ឌខេត្តកំពង់ចាម រោងចក្រវាយនភ័ណ្ឌខេត្តបាត់ដំបង រោងចក្របាវក្រចៅដូនទាវ




ខេត្តបាត់ដំបង រោងចក្រស៊ីម៉ងត៍ចក្រីទីងខេត្តកំពត រោងចក្រកែវជើងឯករាជធានីភ្នំពេញ រោងចក្រក្ដារបន្ទះដីឥដ្ឋខេត្តកណ្ដាល រោងចក្រក្រដាសឆ្លូងខេត្តក្រចេះ រោងចក្រជីហ្វូសស្វាតទូកមាសខេត្តកំពត រោងចក្រកង់ឡានតាខ្មៅខេត្តកណ្ដាល រោងចក្រត្រីខប្រអប់កោះកុង រោងចក្រផលិតជ័រកៅស៊ូជប់ខេត្តកំពង់ចាម រោងចក្រវារីអគ្គិសនីគិរីរម្យខេត្តកំពង់ស្ពឺ និងសមិទ្ធផលនានាជាច្រើនទៀត នៅតាមបណ្តាស្រុក-ខេត្ត-ក្រុង ដូចជាសាលារៀន មន្ទីរពេទ្យ ទំនប់ទឹក ស្រះទឹក ប្រឡាយ ផ្លូវថ្នល់ ស្ពានជាដើម។ល។








# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ស្ពានជ្រោយចង្វារមិត្តភាពកម្ពុជា-ចិន (ស្ពានជ្រោយចង្វារទី២)

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អញ្ជើញជាអធិបតីក្នុងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ស្ពានជ្រោយចង្វារមិត្តភាពកម្ពុជា-ចិន (ស្ពានជ្រោយចង្វារទី២) សួនច្បារវង្វង់មូលស្ពាតចាស់ និងសួនច្បារវង្វង់មូលជ្រោយចង្វារត្រើយខាងកើត។





ពិធីសម្ពោធសមិទ្ធផលថ្មី បានបន្ថែមសោភ័ណភាពរាជធានីភ្នំពេញ ក្នុងទឹកដីជ្រោយចង្វារនេះ មានការអញ្ជើញចូលរួមពីសំណាក់ **ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា លោកស្រី ប៊ូ ជៀនហ្គួ** មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា ប្រជាពលរដ្ឋ យុវជនកាយឫទ្ធិ យុវជនកាកបាទក្រហម និងសិស្សានុសិស្សជាច្រើននាក់ផ្សេងទៀត។ ស្ពានជ្រោយចង្វារមិត្តភាពកម្ពុជា-ចិន គឺជាស្ពានទី៤ ដែល **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញបើកសម្ពោធដាក់ឱ្យប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់នៅក្នុងឆ្នាំ២០១៥នេះ។

ស្ពានជ្រោយចង្វារទី២នេះ គឺជាការតភ្ជាប់សរសៃឈាមថ្មីលើវិថីដឹកជញ្ជូន និងការធ្វើដំណើរឆ្លងកាត់ទន្លេមេគង្គ ហើយក៏បានជួយបញ្ចៀសការកកស្ទះនៅតំបន់នេះផងដែរ។

**ស្ពានជ្រោយចង្វារទី១** ដែលស្ថិតក្នុងរាជធានីភ្នំពេញឬ ស្ពានមិត្តភាពកម្ពុជាជប៉ុនត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩៦៦។ បន្ទាប់ពីប្រជាពលរដ្ឋ ត្រូវបានគេបណ្តេញចេញពីទីក្រុងដោយកងកម្លាំងខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដូច្នេះស្ពានជ្រោយចង្វាររាជធានីភ្នំពេញត្រូវបានគេទុកចោល ដោយគ្មានការជួសជុល ហើយការខូចខាត ព្រោះតែសង្គ្រាម។ បន្ទាប់ពីបានរំដោះនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ចំនួនប្រជាជនខេត្តនិងក្រុងលាយបញ្ចូលគ្នាបានត្រឡប់ទៅរស់នៅក្នុងរាជធានីភ្នំពេញ និងរដ្ឋាភិបាលបានចាប់ផ្តើមស្តារហេដ្ឋារចនាសម្ព័ន្ធនៅរាជធានីភ្នំពេញ ដែលត្រូវបានរងការខូចខាតដោយសង្គ្រាម និងការបោះបង់ចោល។


















សម្តេចតេជោ ហ៊ុន សែន ផ្តល់កិត្តិយសកាត់ខ្សែបូ សម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានជ្រោយចង្វារទី២




## កិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី២

កិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី២ នៅសាលប្រជុំសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ប់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ **ឯកឧត្តម លោកជំទាវ សមាជិក-សមាជិកា ក្រុមប្រឹក្សារាជធានីភ្នំពេញ ឯកឧត្តម ឃួង ស្រេង និងលោកជំទាវ ម៉ក់ វណ្ណសុីថា អភិបាលរងរាជធានីភ្នំពេញ** និងសហការី នាព្រឹកថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ក្នុងរបៀបវារៈចំនួន២ដូចខាងក្រោម៖

១. ពិនិត្យ និងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ។

២. ពិនិត្យ របាយការណ៍របស់សាលារាជធានី ក្នុងត្រីមាសទី៣ឆ្នាំ២០១៥ ដោយក្នុងត្រីមាសនេះរាជធានីភ្នំពេញ បានផ្តល់សៀវភៅគ្រួសារជូនប្រជាពលរដ្ឋបានចំនួន៥៥១សហព័ន្ធ និងបានផ្តល់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរបាន៩២៣៦៣សន្លឹក៕









អាជ្ញាធរមូលដ្ឋានផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ



# ពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១៥-២០១៦ និងចែករង្វាន់សិស្សពូកែ រាជធានីភ្នំពេញ




សិស្សពូកែអន្តរជាតិ សិស្សពូកែជាប់និទ្ទេសA-B សិស្សពូកែទូទាំងប្រទេស សិស្សពូកែរាជធានីភ្នំពេញ សិស្សជ័យលាភីលេខ១ ដល់លេខ៣ សរុបចំនួន ៣.៣៨២ នាក់ (យុវតី ២.២២១ នាក់) នៃវិទ្យាល័យនានា ក្នុងរាជធានីភ្នំពេញ បានជួបជុំគ្នាដើម្បីចូលរួមបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៥-២០១៦ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និង**លោកជំទាវ** ក្នុងបរិវេណវិទ្យាល័យ ជា ស៊ីម បឹងកេងកង នាព្រឹកថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥។



ការផ្តល់រង្វាន់លើកទឹកចិត្តជូនដល់សិស្សពូកែ

ជាការពិតលទ្ធផលល្អដែលសិស្សទទួលបាន នាពេលនេះ គឺសិស្សានុសិស្សខ្លួនឯងផ្ទាល់ ព្យាយាមរៀនសូត្រ ក្នុងនាមជាកូនល្អ សិស្សល្អ មិត្តល្អ ដោយមិនយកពេលវេលា ដ៏មានតម្លៃ ទៅដើរលេងឥតប្រយោជន៍ និងលោកគ្រូ អ្នកគ្រូ យកចិត្តទុកដាក់ខ្ពស់ ក្នុងការបង្រៀន ក្រោមការគ្រប់គ្រងល្អ របស់គណៈនាយកសាលា មាតាបិតា អាណាព្យាបាល តាមដានការសិក្សា និងអប់រំទូន្មានជាប្រចាំ។



ទន្ទឹមនេះផងដែរ **ឯកឧត្តមអភិបាល** ក៏បានសំណូមពរ៖

១. សូមឱ្យគណៈនាយកសាលាមេត្តាផ្សារភ្ជាប់ការសិក្សារបស់សិស្សទៅជាមួយនឹងការងារស្ម័គ្រចិត្តក្នុងសង្គមផ្សេងៗ។

២. សូមឱ្យមានការបើកវេទិកាសាធារណៈនៅតាមសាលានានាក្នុងរាជធានីភ្នំពេញ ឱ្យបានយ៉ាងហោចណាស់ម្តងក្នុង១ឆមាស។

សូមសិស្សានុសិស្ស ឪពុកម្តាយ អាណាព្យាបាល និងលោកគ្រូ អ្នកគ្រូ ចូលរួមពង្រឹងគុណភាពអប់រំទាំងអស់គ្នា៕






# ប្រតិភូសាលារាជធានីភ្នំពេញ ធ្វើដំណើរទស្សនកិច្ចផ្លូវការ នៅទីក្រុងប៉ារីស ប្រទេសបារាំង



ប្រតិភូសាលារាជធានីភ្នំពេញបានធ្វើដំណើរដល់ទីក្រុងប៉ារីស

បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលជាង ១៧ម៉ោង តាមជើងយន្តហោះភ្នំពេញ-បាងកក បាងកក-ប៉ារីស គណៈប្រតិភូសាលារាជធានីភ្នំពេញដឹកនាំដោយ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ** និងលោកជំទាវ រួមដំណើរដោយឯកឧត្តម អភិបាលរង និងមន្ត្រីជាន់ខ្ពស់របស់សាលារាជធានីភ្នំពេញបានអញ្ជើញដល់ព្រលានយន្តហោះអន្តរជាតិ Roissy Charles de Gaulle នៃទីក្រុងប៉ារីស ប្រទេសបារាំង ហើយបាននឹងកំពុងស្នាក់នៅសណ្ឋាគារ Hyatt Regency Paris Etoile។



ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូសាលារាជធានីភ្នំពេញនៅប្រទេសបារាំង និងប្រទេសទុយនេស៊ី មានរយៈពេល ១១ ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៥។ គួសបញ្ជាក់ផងដែរថានៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ គណៈប្រតិភូ



ទិដ្ឋភាពទីក្រុងប៉ារីសនៃប្រទេសបារាំង

សាលារាជធានីភ្នំពេញបានអញ្ជើញចូលជួបសម្ដែងការគួរសមជាមួយ **លោកជំទាវ** ANNE HIDALGO **អភិបាលក្រុងប៉ារីស** អញ្ជើញជួបពិភាក្សាការងារជាមួយទីភ្នាក់ងារនគរូបនីយកម្ម និងរៀបចំក្រុងប៉ារីស ( A P U R ) និងអញ្ជើញជួបពិភាក្សាការងារជាមួយទីចាត់ការគមនាគមន៍ និងដឹកជញ្ជូន ទីក្រុងប៉ារីស៕



នាព្រឹកថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ដដែល គណៈប្រតិភូសាលារាជធានីភ្នំពេញ **ឯកឧត្តម ត្រាក់ ថៃសៀង អភិបាលរងរាជធានីភ្នំពេញ លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការរាជធានីភ្នំពេញ និងលោក សេង វណ្ណៈ នាយករងទីចាត់ការរៀបចំក្រុង** បានចូលជួបពិភាក្សាការងារ ជាមួយ **ឯកឧត្តម** Patrick Klugman អភិបាលរងទីក្រុងប៉ារីស និងសហការី នៅសាលាក្រុងប៉ារីស។



ប្រតិភូជួបពិភាក្សាជាមួយអភិបាលរងក្រុងប៉ារីស និងសហការី

ក្រុមការងារបច្ចេកទេសទាំងពីរ បានពិភាក្សាលម្អិត និងកំណត់យកប្រធានបទសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការងាររៀបចំទីក្រុង ការងារអភិវឌ្ឍន៍ទីក្រុង ការងារអភិវឌ្ឍន៍សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ក្រោយកិច្ចពិភាក្សាក្រុមការងារបច្ចេកទេសទាំងពីរបានធ្វើកំណត់ហេតុរួម និងធ្វើសេចក្ដីព្រាងជូនថ្នាក់ដឹកនាំរៀងខ្លួនដើម្បីចុះសហប្រតិបត្តិការលើការងារខាងលើនេះ។



គួសបញ្ជាក់ផងដែរថា ភាគីទាំងពីរបានវាយតម្លៃយ៉ាងខ្ពស់ចំពោះជំនួបដ៏មានសារៈសំខាន់នេះ ដែលជាជំនួបខ្លី តែមានប្រសិទ្ធភាព ជាមួយនឹងលទ្ធផលជាផ្លែផ្កាដល់កិច្ចសហប្រតិបត្តិការរវាងទីក្រុងទាំងពីរនាពេលកន្លងមកនិងជាពិសេសសំរាប់គម្រោងនានាទៀតនៅពេលអនាគតដ៏ខ្លី សំដៅឆ្ពោះទៅការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។





ប្រតិភូជួបពិភាក្សាជាមួយថ្នាក់ដឹកនាំមន្ទីរជំនាញសាលាក្រុងប៉ារីស

នៅរសៀលថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ក្រុមការងារប្រតិភូសាលារាជធានីភ្នំពេញដឹកនាំដោយ **ឯកឧត្តម ត្រាក់ ថៃសៀង** បានបន្តទៅជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំមន្ទីរនគរូបនីយកម្ម មន្ទីរគមនាគមន៍ និងដឹកជញ្ជូន សាលាក្រុងប៉ារីស។



ក្នុងជំនួបនេះដែរ ភាគីទាំងពីរបានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់លើការងាររៀបចំប្លង់មេនគរូបនីយកម្ម ការងារសាធារណការ និងដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចិញ្ចើមថ្នល់ ការគ្រប់គ្រងសណ្ដាប់ធ្នាប់ចរាចរណ៍ជាដើម សាលាក្រុងប៉ារីសសន្យានឹងផ្ដល់ជាជំនួយផ្នែកបច្ចេកទេសសម្រាប់គម្រោងអភិវឌ្ឍន៍រាជធានីភ្នំពេញ៕





## ការជួបជាមួយទីចាត់ការបច្ចេកទេសរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង



បញ្ហាប្រឈមចំនួនបួនដែលពាក់ព័ន្ធនឹងប្រព័ន្ធលូ-ប្រឡាយ ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ ការគ្រប់គ្រង ទុកដាក់ និងកែច្នៃសំរាម សេវាដឹកជញ្ជូនសាធារណៈរបស់រដ្ឋ ត្រូវបាន **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** រួមនឹងគណៈប្រតិភូសាលារាជធានីភ្នំពេញ យកមកធ្វើជាប្រធានបទដើម្បីពិភាក្សា ពិនិត្យ និងស្វែងរកដំណោះស្រាយជាមួយនឹងមន្ត្រីជាន់ខ្ពស់នៃទីចាត់ការបច្ចេកទេសរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥។



សាលារាជធានីភ្នំពេញ ក៏បានស្នើដល់ទីចាត់ការបច្ចេកទេសរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ផ្តល់ជាជំនួយមកសាលារាជធានីភ្នំពេញលើផ្នែកទន់ ពាក់ព័ន្ធ ឯកសារផ្លូវច្បាប់ នីតិវិធីដោះស្រាយផ្លូវច្បាប់ និងឯកសារមួយចំនួនទៀត និងលើផ្នែករឹងពាក់ព័ន្ធនឹងបច្ចេកទេសគ្រប់គ្រង បច្ចេកទេសដោះស្រាយ និងបណ្តុះបណ្តាលមន្ត្រីរបស់សាលារាជធានីភ្នំពេញ។ ក្នុងនោះទីចាត់ការបច្ចេកទេសរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) រីករាយស្វាគមន៍ចំពោះសំណើទាំងនេះ ហើយសន្យានឹងផ្តល់ជាជំនួយបច្ចេកទេស ដើម្បីជួយដោះស្រាយបញ្ហាខាងលើ រួមទាំងបញ្ជូនមន្ត្រីជំនាញរបស់ខ្លួនដើម្បីមកជួយ និងបណ្តុះបណ្តាលដល់មន្ត្រីសាលារាជធានីភ្នំពេញ៕



## ទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធចរាចរណ៍ទីក្រុងប៉ារីស



គណៈប្រតិភូសាលារាជធានីភ្នំពេញដឹកនាំដោយ **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានទៅបំពេញទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធចរាចរណ៍របស់សាលាក្រុងប៉ារីស នាព្រឹកថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥។

គណៈប្រតិភូបានស្វែងយល់ពីបច្ចេកទេសនៃការប្រើប្រាស់បច្ចេកទេសដោះស្រាយបញ្ហាបច្ចេកទេសបញ្ចៀសចរាចរណ៍ ដែលមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធចរាចរណ៍បាននឹងកំពុងអនុវត្តន៍ផ្ទាល់។



សូមបញ្ជាក់ផងដែរថា នៅបច្ចុប្បន្ននេះទីក្រុងប៉ារីសមានកាមេរ៉ាសុវត្ថិភាពចំនួនប្រមាណជាង ១៨០០គោលដៅ ស្របពេលជាមួយរាជធានីភ្នំពេញមានប្រមាណជាង ២០គោលដៅ ដែលបាននឹងកំពុងដំណើរការក្នុងភូមិសាស្ត្រខណ្ឌកណ្តាលក្រុង ហើយនឹងបន្តអភិវឌ្ឍន៍តម្លើងបន្ថែមទៀតនាពេលអនាគតដ៏ខ្លីខាងមុខនេះ៕



អគារមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធចរាចរណ៍ទីក្រុងប៉ារីស

## ជំនួបលោក Emmanuel LENAIN ប្រធាននាយកដ្ឋានអាស៊ី-អូសេអានី ក្រសួងការបរទេស និងអភិវឌ្ឍន៍អន្តរជាតិ



គណៈប្រតិភូសាលារាជធានីភ្នំពេញ ដែលដឹកនាំដោយ **ឯកឧត្តម ប៉ា សុជាតិវង្ស** បានបន្តចូលជួបពិភាក្សាការងារជាមួយ **លោក** Emmanuel LENAIN ប្រធាននាយកដ្ឋានអាស៊ី-អូសេអានី ក្រសួងការបរទេស និងអភិវឌ្ឍន៍អន្តរជាតិនៃសាធារណរដ្ឋបារាំង នាព្រឹកថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥។

ក្នុងជំនួបដ៏មានអត្ថន័យនេះ **ឯកឧត្តម ប៉ា សុជាតិវង្ស** បានលើកឡើងពីទំនាក់ទំនង នៃសហប្រតិបត្តិការល្អនៃប្រទេសទាំងពីរនិយាយជារួម និយាយដោយឡែករវាងរាជធានីភ្នំពេញ និងរដ្ឋធានីប៉ារីសលើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាច្រើននាពេលកន្លងមក។

បញ្ហារបស់រាជធានីភ្នំពេញដែលកំពុងតែជួបប្រទះពាក់ព័ន្ធនឹងប្រព័ន្ធលូ-ប្រឡាយ ការគ្រប់គ្រងសណ្ដាប់ធ្នាប់សាធារណៈ ការគ្រប់គ្រងទុកដាក់ និងកែច្នៃសំរាម និងសេវាដឹកជញ្ជូនសាធារណៈរបស់រដ្ឋត្រូវបានលើកឡើងព្រមគ្នាក្នុងជំនួបនេះផងដែរ។



ជាលទ្ធផលផ្លែផ្កានៃជំនួបពិភាក្សានេះ សាធារណរដ្ឋបារាំងបានបញ្ជាក់ថាបារាំងបានត្រៀមរួចជាស្រេចនូវជំនួយផ្នែកឥណទានផ្នែកបច្ចេកទេស និងឯកសារផ្លូវច្បាប់ សម្រាប់ដោះស្រាយបញ្ហារបស់រាជធានីភ្នំពេញ៕



## ជំនួបជាមួយលោកស្រី VALERIE MANCRET-TAILOR អគ្គនាយកវិទ្យាស្ថានរៀបចំក្រុង និងនគរូបនីយកម្ម



នៅព្រឹកថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥ ប្រតិភូសាលារាជធានីភ្នំពេញ បានបន្តចូលជួបពិភាក្សាការងារ ជាមួយលោកស្រី VALERIE MANCRET-TAILOR អគ្គនាយកវិទ្យាស្ថានរៀបចំក្រុង និងនគរូបនីយកម្មទីក្រុងនៃសាធារណរដ្ឋបារាំង( IAU ) នៅវិទ្យាស្ថាន។



ក្នុងជំនួបដ៏មានសារៈសំខាន់ **ឯកឧត្តម ប៉ា សុជាតិវង្ស** បានលើកឡើងពីការរៀបចំផែនទីប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញឆ្នាំ២០៣៥ (Master Plan 2035) ដែលបាននឹងកំពុងដំណើរការរៀបចំ ហើយគ្រោងនឹងដាក់ឆ្លងរាជរដ្ឋាភិបាលកម្ពុជានាពេលខាងមុខជូនលោកស្រីអគ្គនាយក និងសហការី ដើម្បីជ្រាប។ ឆ្លើយតបនឹងតម្រូវការរបស់សាលារាជធានីភ្នំពេញលោកស្រី VALERIE MANCRET-TAILOR អគ្គនាយកវិទ្យាស្ថានរៀបចំក្រុង និងនគរូបនីយកម្មទីក្រុង នៃសាធារណរដ្ឋបារាំង (IAU) សន្យាផ្ដល់ជាជំនួយបច្ចេកទេស រួមជាមួយអ្នកបច្ចេកទេស ដើម្បីជួយសិក្សារៀបចំផែនទីប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញឆ្នាំ២០៣៥ ( Master Plan 2035 ) របស់សាលារាជធានីភ្នំពេញ៕



ឯកឧត្តម ប៉ា សុជាតិវង្ស ប្រគល់វត្ថុអនុស្សាវរីយ៍ជូនលោកស្រី

## ជំនួប លោកជំទាវ Anne HIDALGO ប្រធាន AIMF និងជាអភិបាលរដ្ឋធានីប៉ារីស



មុនពេលអញ្ជើញចូលរួមកិច្ចប្រជុំរបស់សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង AIMF នៅព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងទុយនីស ប្រទេសទុយនេស៊ី **ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ** បានអញ្ជើញជួបពិភាក្សាការងារជាមួយ **លោកជំទាវ** Anne HIDALGO **ប្រធាន** AIMF **និងជាអភិបាលរដ្ឋធានីប៉ារីស** ដើម្បីរៀបចំកិច្ចព្រមព្រៀងរួម Paris-Phnom Penh ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងទីក្រុងទាំងពីរលើផ្នែកមួយចំនួនដូចជា៖ ការងារនគរូបនីយកម្ម ការងារគ្រប់គ្រងផែនការទីក្រុង និងការងារដឹកជញ្ជូនសាធារណៈជាដើម។



សាលាក្រុងប៉ារីសនឹងបញ្ជូនអ្នកជំនាញការចុះពិនិត្យស្ថានភាពជាក់ស្តែង នៅរាជធានីភ្នំពេញ ដើម្បីរៀបចំគម្រោងជាក់ស្តែងដើម្បីអនុវត្ត៕





## ដំណើរទស្សនកិច្ចសិក្សាស្វែងយល់ពីការគ្រប់គ្រងសេវាកម្ម និងដំណើរការនៃប្រតិបត្តិការរថភ្លើង Tramway



នៅរសៀលថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥ ប្រតិភូក្រុមការងារសាលារាជធានីភ្នំពេញ ដឹកនាំដោយ **ឯកឧត្តម ម៉ិន សេរី អភិបាលរងរាជធានីភ្នំពេញ រួមដំណើរដោយលោក សំ ពិសិដ្ឋ ប្រធានមន្ទីរ**



**សាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ** បានចុះសិក្សាស្វែងយល់ពីការគ្រប់គ្រងសេវាកម្ម និងដំណើរការនៃប្រតិបត្តិការរថភ្លើង Tramway របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរបស់ទីក្រុងប៉ារីស៕





សិក្សាស្វែងយល់ពីដំណើរការនៃប្រតិបត្តិការរថភ្លើង Tramway



# កិច្ចប្រជុំសមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង AIMF នៅទីក្រុងទុយនីស



នៅព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ **អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ឯកឧត្តម ប៉ា សុជាតិវង្ស** បានអញ្ជើញចូលរួមពិធីបើកកិច្ចប្រជុំសមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង AIMF នៅទីក្រុងទុយនីស ប្រទេសទុយនេស៊ី ក្រោមអធិបតីភាព **ឯកឧត្តម** Habib Essid,នាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋទុយនេស៊ី **លោកជំទាវ** Anne HIDALGO **ប្រធាន** AIMF **និងជាអភិបាលរដ្ឋធានីប៉ារីស** រួមជាមួយ ឯកឧត្តម លោកជំទាវជាអភិបាលក្រុងប្រើប្រាស់ភាសាបារាំងនៅលើពិភពលោកផងដែរ។





កិច្ចប្រជុំផ្តោតសំខាន់លើ បញ្ហាបរិស្ថាន ការប្រែប្រួលអាកាសធាតុ ថាមពលបៃតង និងតំរង់ទិសដៅឱ្យការប្រជុំទីក្រុងជាង ១000 នៅប៉ារីស នាខែធ្នូខាងមុខនេះ៕









## ពិធីក្រុងពាលី និងអភិសេករូបសំណាកព្រះព្រហ្មមុខបួន នៅរង្វង់មូលជ្រោយចង្វារ

ពីធីបែបសាសនា ដែលប្រារព្ធធ្វើឡើងនារសៀលថ្ងៃនេះ គឺដើម្បីសុំសេចក្តីសុខសេចក្តីចម្រើន ជូនដល់ប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ ឬចូលលេងកម្សាន្ត នៅពេលសមិទ្ធផលទាំងនេះត្រូវបានដាក់ឱ្យដំណើរការ។



ពិធីក្រុងពាលី និងអភិសេករូបសំណាកព្រះព្រហ្មមុខបួន ក្រោមអធិបតីភាព ឯកឧត្តម ប៉ា សុជាតិវង្ស និងលោកជំទាវ និងមន្ត្រីរាជការសាលារាជធានីភ្នំពេញ យុវជន ប្រជាពលរដ្ឋ និងពុទ្ធបរិស័ទប្រមាណ ៥០០នាក់។

ចម្លាក់ព្រហ្មបាយ័ន យកលំនាំដើមពីប្រាសាទបាយ័ន ក្នុងខេត្តសៀមរាប ដោយធ្វើអំពីថ្មភ្នំយកពីខេត្តព្រះវិហារ កាត់ឆ្លាក់ជាប់ជាដុំៗ បន្តុបលើគ្នា មានកំពស់ ៩.១៨ម៉ែត្រ ទទឹង ៦.៣០ម៉ែត្រ។

រូបចម្លាក់ព្រហ្មបាយ័ន តំណាងអោយព្រះភ័ក្ត្ររបស់ព្រះលោកេស្វរៈ ជាព្រះពោធិសត្វនៃពុទ្ធសាសនាមហាយាន ដែលមានមហាករុណាចំពោះមនុស្សលោកគ្រប់ទិសទាំង៤ ដែលបងប្អូនប្រជាពលរដ្ឋខ្មែរយើងតែងតែនិយមហៅឈ្មោះថាជា ព្រហ្មបាយ័ន ឬព្រហ្មមុខ៤។



ឯកឧត្តម ប៉ា សុជាតិវង្ស អញ្ជើញចូលរួមក្នុងពិធី

ព្រហ្មបាយ័ន មានព្រះភ័ក្ត្រញញឹម បែរទៅរកកូនចៅខ្មែរគ្រប់ទិសទី ប្រកបដោយព្រហ្មវិហារធម៌ ៤ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា។ ព្រហ្មវិហារធម៌ទាំង៤នេះ គឺជាមូលដ្ឋានសំខាន់ សម្រាប់ស្ថាបនានូវសុខសន្តិភាពនិងវប្បធម៌អហឹង្សាក្នុងសង្គមខ្មែរ ៕















# កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ស្តីពីផែនការ ការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងពេលប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក



នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ** បានបើកកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ស្តីពីផែនការការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងពេលប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក។ ដោយអង្គប្រជុំបានដាក់ជាផែនការចំនួន៤ចំណុចខាងក្រោម៖

១. បង្កើតអនុគណៈកម្មការជំនាញ ក្នុងការរៀបចំប្លង់ទីតាំង សម្រាប់បងប្អូនមកកម្សាន្ត តំបន់កម្សាន្ត លក់ទំនិញ និងកន្លែងប្រគំតន្ត្រី។

២. ផែនការការពារសន្តិសុខសណ្តាប់ធ្នាប់ និងប្រព័ន្ធចរាចរណ៍នៅក្នុងអំឡុងពេលព្រះរាជពិធីបុណ្យ។

៣. រៀបចំផែនការការងារសណ្តាប់ធ្នាប់អនាម័យ ក្នុងរាជធានីភ្នំពេញ មុនពេលពិធីបុណ្យ ពេលពិធីបុណ្យ និងក្រោយពេលពិធីបុណ្យ។

៤. រៀបចំតុបតែលំអ សួនច្បារ ភ្លើងពណ៌នៅតាមដងផ្លូវ សម្រាប់អបអរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ២០១៥។













# វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី អាណត្តិទី២ នៅខណ្ឌទួលគោក

ស្របតាមកំណែទម្រង់ស៊ីជម្រៅ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព របស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការកែលម្អ ការផ្តល់សេវាសាធារណៈរបស់ខ្លួន នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលវប្បធម៌ចេនឡា មានបើកវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី អាណត្តិទី២ នៅខណ្ឌទួលគោក ក្រោមអធិបតីភាព **ឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី ប្រធាន**







**ក្រុមការងារថ្នាក់ជាតិចុះជួយខណ្ឌទួលគោក ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និង **ឯកឧត្តម ស្លួន រិនឌី តំណាងប្រធានក្រុមប្រឹក្សារាជធានី** ដោយមានការចូលរួមពីមន្ត្រីរាជការ និងប្រជាពលរដ្ឋប្រមាណ៥០០នាក់។ ដោយវេទិកានេះបានផ្តល់ឱកាសអោយប្រជាពលរដ្ឋអាចបង្ហាញនូវការលំបាក ជូនដល់ថ្នាក់ដឹកនាំផ្ទាល់ គឺជាមួយក្រុមប្រឹក្សារាជធានីភ្នំពេញ លើប្រធានបទនានា ដូចជា៖ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការងារអភិវឌ្ឍមូលដ្ឋាន និងការងារបរិស្ថាន។ល។ សម្រាប់លទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ កន្លងមក សម្រេចបាន ការដោះស្រាយបញ្ហារួចចំនួន ៧៧បញ្ហា បានសិក្សាដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរួច ចំនួន ១៦បញ្ហា ជូនបងប្អូនប្រជាពលរដ្ឋ លើការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការងារអភិវឌ្ឍមូលដ្ឋាន និងការងារបរិស្ថាន៕








## ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង



ការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ គឺក្នុងគោលបំណងដើម្បីផ្តល់នូវផលប្រយោជន៍ដល់ប្រជាពលរដ្ឋ រួមមានបង្កភាពងាយស្រួលក្នុងការធ្វើដំណើរ ធានាសុវត្ថិភាព ផាសុកភាព សន្សំសំចៃពេលវេលា កាត់បន្ថយការកកស្ទះចរាចរណ៍ ការប្រើប្រាស់ថាមពលខ្ជះខ្ជាយ ឧស្ម័នបំពុលបរិស្ថាន និងផលប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** ។

ទន្ទឹមនេះ ក៏មានបញ្ហាជាច្រើនបាននឹងកំពុងជួបប្រទះចំពោះដំណើរការរថយន្តក្រុងសាធារណៈបណ្តោះអាសន្នរយៈពេលជិត១ឆ្នាំនាពេលកន្លងមក គឺយើងបានខាតបង់ប្រាក់ជាច្រើនក្នុង១ខែៗ ដូចជាការគ្រប់គ្រងលក់សំបុត្រមិនទាន់ត្រឹមត្រូវ ការចំណាយទៅលើការជួសជុលរថយន្ត និងការចំណាយទៅលើពលកម្មជាដើម។ តែទោះយ៉ាងណាសាលារាជធានីភ្នំពេញ និងជំនះរាល់ឧបសគ្គទាំងឡាយដែលកំពុងកើតឡើង ដើម្បីឱ្យសេវាសាធារណៈមួយនេះ អាចដំណើរការបាន និងមាននិរន្តរភាព។



ក្នុងឱកាសនោះដែរ **ឯកឧត្តមអភិបាល** ក៏បានសំណូមពរសូមឱ្យបងប្អូនប្រជាពលរដ្ឋបន្តចូលរួម និងគាំទ្រនូវសេវាដឹកជញ្ជូនសាធារណៈរបស់សាលារាជធានីភ្នំពេញនេះបន្តទៀត៕






# ខ្សែរថយន្តក្រុងនឹងដំណើរការក្នុងជំហានដំបូងរបស់សាលារាជធានីភ្នំពេញ (៣ខ្សែ)



## ផែនទីខ្សែរត់ ចំនួន៣ខ្សែរបស់រថយន្តក្រុងនឹងដំណើរការក្នុងជំហានដំបូង

ផែនទីតំរាយផ្លូវខ្សែរត់ទី១(A)



ផែនទីតំរាយផ្លូវខ្សែរត់ទី២(B)



ផែនទីតំរាយផ្លូវខ្សែរត់ទី៣(C)





# ពិធីសម្ពោធអគារស្នាក់នៅសម្រាប់កងទ័ព និងរោងរថក្រោះរបស់បញ្ជាការដ្ឋានអង្គរក្ស

នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ **ឯកឧត្តម ប៉ា សុជាតិវង្ស** **អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធអគារស្នាក់នៅសម្រាប់កងទ័ព និងរោងរថក្រោះ









ឯកឧត្តម ប៉ា សុជាតិវង្ស អញ្ជើញមានមតិសំណេះសំណាលក្នុងពិធី

របស់បញ្ជាការដ្ឋានអង្គរក្ស ដែលជាជំនួយរបស់សប្បុរសជននានា ក្រោមគំនិតផ្តួចផ្តើម **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងអង្គរក្ស។

រាជរដ្ឋាភិបាលកម្ពុជាក្នុងពេលបច្ចុប្បន្ន បាននឹងកំពុងផ្សារភ្ជាប់សមរភូមិជួរមុខ និងសមរភូមិជួរក្រោយ ឱ្យមានភាពស្អិតរមួត ហើយកំពុងធ្វើឱ្យសមរភូមិទាំងពីរមានដំណើរ នៅក្នុងបុព្វហេតុជាតិតែមួយដោយមិនអាចខ្វះមួយណាបាន។ ការចែករំលែកសុខទុក្ខជាមួយគ្នារវាងសមរភូមិទាំងពីរ គឺជាចំនុចខ្លាំងរវាងកងទ័ព និងអាជ្ញាធរ ហើយបានជះឥទ្ធិពលលើការការពារមាតុភូមិ និងការអភិវឌ្ឍន៍មាតុភូមិរបស់យើង ដែលយើងចាំបាច់ត្រូវតែបន្តប្រពៃណីដ៏ល្អនេះបន្តទៅទៀត៕

# សាលារាជធានីភ្នំពេញ បានបើកកិច្ចប្រជុំស្តីពី គម្រោងប្រាំងទន្លេ សួនវិមានឯករាជ្យ រមណីយដ្ឋានវត្តភ្នំ និងសួនរង្វង់មូលខាងកើតស្ពានជ្រោយចង្វារ






ដើម្បីកែលម្អសោភ័ណភាពរាជធានីភ្នំពេញឱ្យកាន់តែប្រសើរឡើងថែមទៀត ក្នុងលក្ខខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជធានីភ្នំពេញ សាលារាជធានីភ្នំពេញបាននឹងកំពុងខិតខំស្ថាបនាគម្រោងហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើន។ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ នៅសាលារាជធានីភ្នំពេញមានកិច្ចប្រជុំស្តីពីគម្រោងប្រាំងទន្លេ សួនវិមានឯករាជ្យ





រមណីយដ្ឋានវត្តភ្នំ និងសួនរង្វង់មូលខាងកើតស្ពានជ្រោយចង្វារ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ** រួមជាមួយមន្ត្រីជំនាញសាលារាជធានីភ្នំពេញ និងមន្ទីរដែលពាក់ព័ន្ធនានា។



កិច្ចប្រជុំបានពិភាក្សាលើការត្រួតពិនិត្យការងារការដ្ឋាននៃគម្រោងទាំង៤ និងបញ្ហាប្រឈមនានាដែលកើតមានដូចជា៖ .
-ការដាក់លូនៅគម្រោងជួសជុលនិងកែលម្អរមណីយដ្ឋានវត្តភ្នំដើម្បីជៀសវាងការលិចលង់ដែលមានកន្លងមក
-ការសិក្សាពីលទ្ធភាពសម្រួលចរាចរណ៍ លើគម្រោងរមណីយដ្ឋានវត្តភ្នំ និងគម្រោងស្ថាបនាសួនរង្វង់មូលខាងកើតស្ពានជ្រោយចង្វារ។

គម្រោងស្ថាបនាសួនរង្វង់មូលខាងកើតស្ពានជ្រោយចង្វារ ដែលការដ្ឋាននឹងបញ្ចប់ទាំងស្រុងនៅថ្ងៃទី១៥ខែតុលាឆ្នាំ២០១៥៕





# ថ្នាក់ដឹកនាំសាលារាជធានីភ្នំពេញ ទទួលជួបអភិបាលរងទីក្រុងគីតាគ្យូស្យូ(Kitakyushu)





ការថតរូបអនុស្សាវរីយ៍ដើម្បីរឹតចំណងមេត្រីភាព

ក្នុងនាមជាទីក្រុងសម្ព័ន្ធមិត្ត បងប្អូន ទីក្រុងគីតាគ្យូស្យូ (Kitakyushu) នៃរាជាណាចក្រជប៉ុន បានជួយដោះស្រាយបញ្ហាកំពុងជួបប្រទះរបស់រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា លើផ្នែកប្រព្រឹត្តកម្មប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូ-ប្រឡាយ និងវិស័យជាច្រើនទៀត។

ដើម្បីបន្តរឹតចំណងមិត្តភាពរវាងទីក្រុងទាំង២ ឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត នៅព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** បានទទួលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម Umemoto Kazuhide អភិបាលរងទីក្រុងគីតាគ្យូស្យូ**(Kitakyushu) និងពិភាក្សាការងារនៅសាលារាជធានីភ្នំពេញ។ ក្នុងកិច្ចពិភាក្សានេះដែរ **ឯកឧត្តម** Umemoto Kazuhide ក៏សូមអញ្ជើញ **ឯកឧត្តមអភិបាលរាជធានីភ្នំពេញ**ទៅទស្សនកិច្ចផ្លូវការនៅទីក្រុងគីតាគ្យូស្យូ នៅពេលសមស្របខាងមុខ៕



ទិដ្ឋភាពនៅក្នុងរាជធានីភ្នំពេញ



ទិដ្ឋភាពនៅទីក្រុងគីតាគ្យូស្យូ(Kitakyushu)




## ប្រតិភូសាលារាជធានីភ្នំពេញជួបពិភាក្សាការងារជាមួយ អនុប្រធានធនាគារពិភពលោក

នារសៀលថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ បានជួបពិភាក្សាការងារជាមួយ **លោក អាក់សែល វ៉ាន់ ត្រូតសេនស្បើប** (Axel Van Trotseburg) **អនុប្រធានធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក** នៅសាលារាជធានីភ្នំពេញ។ ក្នុងជំនួបពិភាក្សានេះលោកអនុប្រធានធនាគារពិភពលោកបានលើកសរសើរពីការអភិវឌ្ឍន៍នៅកម្ពុជា ក៏ដូចជារាជធានីភ្នំពេញចំពោះហេដ្ឋារចនាសម្ព័ន្ធ ការកាត់បន្ថយភាពក្រីក្រ។

ជាងនេះទៅទៀតចំពោះរាជធានីភ្នំពេញ **លោក អាក់សែល វ៉ាន់** បានលើកសរសើរពីការខិតខំប្រឹងប្រែងរបស់គណៈអភិបាលរាជធានីភ្នំពេញ ក្នុងការអភិវឌ្ឍន៍ ជាពិសេសក្នុងការដោះស្រាយនូវបញ្ហាដែលស្មុគស្មាញ ដូចមានករណីបឹងកក់ បុរីកីឡា ជាដើម។

ក្នុងជំនួបដ៏មានសារៈសំខាន់នេះ ធនាគារពិភពលោកសន្យានឹងជួយបំពេញនូវតម្រូវការរបស់រាជធានីភ្នំពេញ លើការងារអភិវឌ្ឍន៍ប្រព័ន្ធលូ ប្រឡាយ ការបង្ហូរទឹកកខ្វក់ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត និងការអភិវឌ្ឍន៍សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ ដែលស្ថិតនៅក្នុងគម្រោងផែនការគោលលម្អិតឆ្នាំ២០៣៥ (Master Plan ២០៣៥) ដែលនឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាសម្រេចនាចុងឆ្នាំ២០១៥នេះ៕









ការផ្តល់កិត្តិយសថតរូបអនុស្សាវរីយ៍រវាងប្រតិភូទាំងពីរ



# កិច្ចប្រជុំបញ្ជៀសការកកស្ទះចរាចរណ៍នៅតាមច្រកចេញ-ចូលរាជធានីភ្នំពេញ ក្នុងរដូវបុណ្យទាន

នៅសាលារាជធានីភ្នំពេញ នារសៀលថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ **ឯកឧត្តម ឃួង ស្រេង អភិបាលរងរាជធានីភ្នំពេញ** បានដឹកនាំកិច្ចប្រជុំមួយស្តីពីការបញ្ជៀសការកកស្ទះចរាចរណ៍នៅតាមច្រកចេញ-ចូលរាជធានីភ្នំពេញ នាឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខ។



ក្នុងឱកាសនោះ **ឯកឧត្តម** ក៏បានគូសបញ្ជាក់ថា រៀងរាល់បុណ្យទានម្តងៗ ប្រជាពលរដ្ឋតែងតែមានការលំបាកនឹងការកកស្ទះចរាចរណ៍នៅតាមច្រកចេញ-ចូលនានា និងបញ្ហាចោរកម្មនានាក្នុងរាជធានីភ្នំពេញ ដូច្នេះអាជ្ញាធរ និងកម្លាំងសមត្ថកិច្ចត្រូវអនុវត្តនូវការងារមួយចំនួនដូចជា៖

១- អភិបាលខណ្ឌទាំងអស់ ត្រូវប្រជុំគណៈបញ្ជាការឯកភាពខណ្ឌរៀបចំកម្លាំងតាមគោលដៅប្រឈមនានានៃច្រកចេញ-ចូលសំខាន់ៗ។





២- កម្លាំងមានសមត្ថកិច្ចត្រូវពង្រឹងការល្បាត ដើម្បីការពារទ្រព្យសម្បត្តិរបស់បងប្អូនដែលទៅជួបជុំសាច់ញាតិនៅស្រុកកំណើត។

៣- ជូនដំណឹងដល់បងប្អូនឱ្យទុកដាក់ផ្ទះសំបែងឱ្យបានត្រឹមត្រូវបង្ការគ្រោះថ្នាក់ ដូចជាអគ្គិភ័យជាដើម៕





កងកម្លាំងសមត្ថកិច្ចតែងជួយសម្រួលការកកស្ទះចរាចរណ៍



## សិក្ខាសាលា ស្តីពី "ការកកស្ទះចរាចរណ៍នៅកម្ពុជា ប៉ះពាល់ដល់បរិស្ថាន និងសុខុមាលភាព"

នាថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ នៅរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំបង្កើតសិក្ខាសាលា ស្តីពី "ការកកស្ទះចរាចរណ៍នៅកម្ពុជា ដែលប៉ះពាល់ដល់បរិស្ថាន និង សុខុមាលភាព៖ បញ្ហាប្រឈម និងដំណោះស្រាយ" ក្រោម



អធិបតីភាព **ឯកឧត្តមបណ្ឌិត្យសភាចារ្យ ស៊ុំ ឈុំប៊ុន អនុប្រធាន រាជបណ្ឌិត្យសភាកម្ពុជា** និង **ឯកឧត្តម អៀង អួនលី អភិបាលរង រាជធានីភ្នំពេញ**។

ដោយអង្គសិក្ខាសាលាបានអញ្ជើញវាគ្មិនមកពីគ្រប់ស្ថាប័ន អង្គការនានា ដើម្បីមកធ្វើបទបង្ហាញស្តីអំពីបញ្ហាប្រឈម និង ដំណោះស្រាយ ទាក់ទងនឹងប្រធានបទខាងលើ សំនួរចម្លើយ និង កិច្ចពិភាក្សាតុមូល ជារបៀបវារៈ នៃដំណើរការសិក្ខាសាលា រយៈពេលពីរថ្ងៃនេះ។



របាយការណ៍របស់ប៉ូលិសចរាចរណ៍បានបង្ហាញថា នៅក្នុង រយៈពេល ១១ខែ ក្នុងឆ្នាំ២០១៥នេះ ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ មានចំនួន ២.២៦៥នាក់ គឺមានការកើនឡើង ១១៧នាក់ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០១៤។ ក៏ប៉ុន្តែនៅក្នុងរយៈពេល ១១ខែក្នុងឆ្នាំ២០១៥ ករណីគ្រោះថ្នាក់ចរាចរណ៍ មានការថយចុះយ៉ាងហោចណាស់ ៥ភាគរយ បើធៀប នឹងឆ្នាំ២០១៤។

របាយការណ៍បង្ហាញថា ការកើនឡើងនៃចំនួនអ្នកស្លាប់ ដោយសារគ្រោះថ្នាក់ចរាចរណ៍ ក្នុងរយៈពេល ១១ខែ ក្នុងឆ្នាំ ២០១៥ នេះ កើតឡើងលើជនរងគ្រោះមានចំនួនច្រើននាក់ ក្នុង មួយករណីៗ ដូចជាករណីរថយន្តដឹកកម្មករនៅក្នុងខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង និងគ្រោះថ្នាក់ នៅឧត្តមានជ័យ ជាដើម។







# ផ្លូវលេខ២៧១ បានដំណើរការចាក់អ៊ុតកៅស៊ូបានជាង៤០% លើប្រវែងសរុប ៧.៧០០ម៉ែត្រ

គិតមកត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ផ្លូវលេខ២៧១ បានដំណើរការចាក់អ៊ុតកៅស៊ូបានជាង៤០%ហើយលើប្រវែងសរុប ៧.៧០០ម៉ែត្រ លាតសន្ធឹងកាត់តាមភូមិសាស្ត្រខណ្ឌទួលគោក និងខណ្ឌចំការមនដែលចាប់ពីមហាវិថីសហព័ន្ធរុស្ស៊ី ដល់ស្ពានអាកាសក្បាលថ្នល់មានទំហំទទឹងចាប់ពី ១៧ម៉ែត្រ ទៅដល់ ១៩ម៉ែត្រ។

ដំណើរការអ៊ុតកៅស៊ូមានភាពយឺតយ៉ាវខ្លះ ដោយសារតែភ្លៀងធ្លាក់ខ្លាំងមិនអាចអ៊ុតបាន បញ្ហាកកស្ទះចរាចរណ៍ជាដើម ហើយនៅទីតាំងខ្លះទៀតតម្រូវឱ្យមានការចាក់អ៊ុតនៅពេលយប់ដើម្បីកុំឱ្យស្ទះចរាចរណ៍។





ផ្លូវលេខ២៧១ មានប្រវែង៧.៧០០ម៉ែត្រ និងទទឹងពី១៧-១៩ម៉ែត្រ

គួរបញ្ជាក់ដែរថា៖ ផ្លូវលេខ២៧១នេះ បានស្ថាបនាឡើងកាលពីអំឡុងឆ្នាំ១៩៩៩ ជាប្រភេទផ្លូវអ៊ុតកៅស៊ូAC គឺបានប្រើប្រាស់អស់រយៈពេល១៦ឆ្នាំ ធ្វើឱ្យផ្លូវនេះមានសភាពទ្រុឌទ្រោម សឹករិចរិលទៅតាមទីតាំងមួយចំនួន ដូច្នេះតម្រូវឱ្យសាលារាជធានីភ្នំពេញធ្វើការជួសជុលកែលម្អផ្លូវនេះឡើងវិញ។ ផ្លូវលេខ២៧១ មានតួនាទីជាផ្លូវក្រវាត់ក្រុងទី១ តភ្ជាប់ចរាចរណ៍ពីតំបន់ខាងជើងរាជធានីភ្នំពេញ ទៅតំបន់ខាងត្បូង និងខាងកើតរាជធានីភ្នំពេញឆ្ពោះទៅក្រុងតាខ្មៅ និងផ្លូវជាតិលេខ២១។

សាលារាជធានីភ្នំពេញ សំណូមពរដល់អ្នកធ្វើដំណើរទាំងឡាយ សូមមេត្តាមានការយោគយល់ចំពោះផលប៉ះពាល់ខ្លះៗនៅពេលដំណើរការជួសជុលផ្លូវ កំពុងតែប្រព្រឹត្តទៅនៅពេលនេះ៕








## សាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ទទួលទេយ្យទានពីព្រះគ្រូសាសននុរក្ខិតវង្ស សោម ស៊ីម

សាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ទទួលទេយ្យទានពី **ព្រះគ្រូសាសននុរក្ខិតវង្ស សោម ស៊ីម ព្រះធម្មធរ អនុគណខណ្ឌព្រែកព្នៅ** និងជា**ព្រះចៅអធិការវត្តប្រាសាទ សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ** ក្រោមអធិបតីភាព **លោកជំទាវ អ៊ួន សុវណ្ណរិទ្ធ ប៉ាសុជាតិវង្ស អនុប្រធានកិត្តិយសសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ** និង សមាជិក សមាជិកាសាខាជាច្រើនរូប។



ទេយ្យទានដែលទទួលបានពី **ព្រះគ្រូសាសននុរក្ខិតវង្ស** ក្នុងឱកាសដ៏ថ្លៃថ្លានោះ រួមមាន អង្ករ ២.០០០គីឡូក្រាម មី ១០០កេសតូច ទឹកក្រូច ២០កេស សម្ភារៈប្រើប្រាស់ ៦សម្រាប់ ស្ករស ៣០០គីឡូក្រាម ទឹកដោះគោ ២០០កំប៉ុង ត្រីខ ៧០០កំប៉ុង ទឹកបរិសុទ្ធ ២០កេស ទឹកត្រី ៣០យួរ ទឹកស៊ីអ៊ីវ ៣០យួរ ថវិកាចំនួន ៣.០០០ដុល្លារ សរុបទឹកប្រាក់ចំនួន ៥.៨៨៥ដុល្លារ។ ក្នុងឱកាសនោះផងដែរ លោកជំទាវក៏បានសំណេះសំណាលសាកសួរសុខទុក្ខ និងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន ពិសេស**ព្រះគ្រូសាសននុរក្ខិតវង្ស សោម ស៊ីម** ដែលបានចូលរួមឧបត្ថម្ភគាំទ្រក្នុងសកម្មភាពមនុស្សធម៌ជាមួយកាកបាទក្រហមកម្ពុជា ហើយទេយ្យទានដ៏ថ្លៃថ្លាទាំងនេះ **លោកជំទាវ** នឹងយកទៅប្រើប្រាស់ឱ្យបានចំទិសដៅស្របតាមគោលការណ៍របស់កាកបាទក្រហមកម្ពុជា៕



លោកជំទាវ អ៊ួន សុវណ្ណរិទ្ធ សំណេះសំណាល និងអំណរគុណសប្បុរសជន






# អាជ្ញាធររាជធានីភ្នំពេញ ចុះពិនិត្យ និងរុះរើផ្ទាំងប៉ាណូផ្សាយពាណិជ្ជកម្មគ្មានសណ្តាប់ធ្នាប់

នៅពេលកន្លងមកនេះ គេតែងសង្កេតឃើញថា ផ្ទាំងផ្សាយពាណិជ្ជកម្ម មួយចំនួនក្នុងរាជធានីភ្នំពេញ ត្រូវបានបាក់ដួលរលំនៅពេលមានភ្លៀង ខ្យល់ខ្លាំង ហើយមួយចំនួនទៀតសង់ជាប់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ប្រព័ន្ធលូ និងកន្លែងហាមឃាត់ជាដើម។



ក្រុមការងារចុះរុះរើផ្ទាំងផ្សព្វផ្សាយជាមួយអាជ្ញាធរខណ្ឌទួលគោក

**ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាល **រាជធានីភ្នំពេញ** ធ្លាប់មានប្រសាសន៍ថា ផ្ទាំងប៉ាណូផ្សព្វផ្សាយពាណិជកម្មបច្ចុប្បន្នគឺ កើតមានច្រើនពេកហើយក្នុងរាជធានីភ្នំពេញ សាលារាជធានី





អាជ្ញាធរចុះរុះរើផ្ទាំងផ្សព្វផ្សាយតាមបណ្តោយមហាវិថីរុស្ស៊ី

ភ្នំពេញនឹងកាត់បន្ថយផ្ទាំងផ្សាយពាណិជ្ជកម្មនេះ ឱ្យនៅកម្រិតមួយសមស្រប មិនឱ្យប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់ទីក្រុង។

ក្រោយពីបានទទួលគោលការណ៍ណែនាំផ្ទាល់ពី **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ក្រុម



ក្រុមការងារចុះពិនិត្យទីតាំងស្នើសុំ AUPP នៅជាប់ផ្លូវ ៥៩៨

ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសទីតាំងផ្ទាំងផ្សាយពាណិជ្ជកម្ម តែងតែបានចុះពិនិត្យ និងរុះរើផ្ទាល់នូវគោមភ្លើង ប្រអប់ភ្លើង LED ផ្ទាំងផ្សាយពាណិជ្ជកម្មណាដែលបានសាងសង់ដោយមិនមានច្បាប់អនុញ្ញាត និងបង្កឱ្យមានផលប៉ះពាល់ដល់គំហើញ សោភ័ណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងរាជធានីភ្នំពេញ។

ក្រុមការងាររបស់សាលារាជធានីភ្នំពេញ តែងបានសហការជាមួយសាលាខណ្ឌទាំង១២ ចុះពិនិត្យ និងរុះរើគោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយពាណិជ្ជកម្មជាច្រើនទីតាំង ដាក់លើចិញ្ចើមផ្លូវថ្មើរជើង ដែលបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ តាមដងវិថីនានា។



ក្រុមការងារចុះពិនិត្យទីតាំងដែលសាកលវិទ្យាល័យ AUPPស្នើសុំ

ក្រោយពីបានអនុវត្តវិធានការរដ្ឋបាលបានមួយជំហានរួចមក យើងសង្កេតឃើញថា នៅតាមបណ្តោយផ្លូវមួយចំនួនក្នុងរាជធានីភ្នំពេញមានសណ្តាប់ធ្នាប់ និងសោភ័ណភាពប្រសើរឡើងវិញ ហើយបងប្អូនប្រជាពលរដ្ឋមានការគាំទ្រចំពោះចំណាត់ការនេះ ព្រមទាំងបានស្ម័គ្រចិត្តរុះរើគោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយដោយខ្លួនឯង ហើយជាពិសេសថែមទៀតនោះ គឺបណ្តាក្រុមហ៊ុនដែលជាប្រភពផ្គត់ផ្គង់សំខាន់ៗ ក៏បានចុះកាត់គោមភ្លើង ប្រអប់ភ្លើង និងផ្ទាំងផ្សាយពាណិជ្ជកម្មដោយខ្លួនឯងដែរ។ ទន្ទឹមនេះ ក្រុមការងារបានសំណូមពរដល់ក្រុមហ៊ុនឱ្យបញ្ឈប់ការផ្គត់ផ្គង់សម្ភារៈផ្សព្វផ្សាយ ដែលនាំឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ៕



ក្រុមការងារចុះពិនិត្យ និងណែនាំទីតាំងដែលក្រុមហ៊ុនស្នើសុំ

# គម្រោងស្ថាបនាផ្លូវថ្មើរជើង តាមមាត់ទន្លេដំណាក់កាលទី១ របស់សាលារាជធានីភ្នំពេញ



គម្រោងស្ថាបនាផ្លូវថ្មើរជើង តាមមាត់ទន្លេដំណាក់កាលទី១ បាននឹងកំពុងចាប់ផ្តើមស្ថាបនាជាបន្តបន្ទាប់ ហើយបានទទួលការគាំទ្រ និងការកោតសរសើរយ៉ាងខ្លាំងពីសំណាក់អាជ្ញាធរនៅក្នុងមូលដ្ឋាន ថ្នាក់ដឹកនាំ ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេស។

គម្រោងនេះ និងតភ្ជាប់ពីបញ្ចរព័ត៌មានទេសចរណ៍នៅមុខព្រះបរមរាជវាំង រហូតដល់ស្ពានភ្លោះកោះពេជ្រ ដែលមានប្រវែងសរុបប្រហែល ៩៥០ម៉ែត្រ ដោយឆ្លងកាត់សាលមហោស្រពចតុមុខ សណ្ឋាគារHimawari និងសណ្ឋាគារCambodiana ក្នុងគោលបំណងពង្រីកបន្ថែមផ្លូវដើរថ្មើរជើង និងសួនច្បារសាធារណៈ ដើម្បីកែលម្អសោភ័ណភាពរាជធានីភ្នំពេញឱ្យកាន់តែប្រសើរឡើងថែមទៀត ដែលជាប្រយោជន៍ដល់សាធារណជនបានកម្សាន្ត លំហែកាយ សោភ័ណភាពរាជធានីភ្នំពេញ និងលំហាត់ប្រាណ ក្នុងលក្ខខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់សាលារាជធានីភ្នំពេញ។














ប្លង់ជាក់ស្តែងមើលពីលើ



ប្លង់ស្ថាបត្យកម្មមើលពីលើ

# បងប្អូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញមានក្តីសង្ឃឹមថ្មី និងការគាំទ្រពេញទំហឹង ចំពោះការពង្រីក និងពង្រឹងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ប្រឡាយ-លូ របស់សាលារាជធានី






កន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន សាលារាជធានីភ្នំពេញបានយកចិត្តទុកដាក់ខ្ពស់ចំពោះការពង្រីក និងពង្រឹងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ។ ការស្តាបនាប្រឡាយ-លូ ក៏បានក្លាយជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យនានារបស់សាលារាជធានីភ្នំពេញ ដើម្បីកាត់បន្ថយបញ្ហាទឹកជន់លិចក្នុងទីក្រុង ហើយដាក់ស្តែងការដ្ឋានស្តាបនាប្រឡាយ-លូជាច្រើនទីតាំងក្នុងរាជធានីភ្នំពេញ ត្រូវបានពន្លឿនក្នុងការសាងសង់ ដែលក្នុងនោះមានដូចជា៖

- ការដ្ឋានដាក់លូប្រអប់តាមបណ្តោយផ្លូវK5 បាន ចំនួន ២៦ប្រអប់ ហើយគ្រោងនឹងបញ្ចប់នាពេលឆាប់ៗនេះ
- ការដ្ឋានប្រឡាយបាក់ទូក គ្រឿងចក្រចាប់ស្តារប្រឡាយនិងកាយ



ល្បាប់ដាក់ធ្វើផ្លូវបានប្រវែង៦០ម៉ែត្រ ដែលការដ្ឋាននេះ ពិតជាមានសារៈសំខាន់ណាស់ ព្រោះវានឹងរំដោះទឹកភ្លៀង និងទឹកសំណល់ចំនួន ៣តំបន់ ដើម្បីនាំទឹកទៅកាន់ស្ថានីយ៍បូមទឹកកប់ស្រូវ និងទ្វារទឹកគីឡូម៉ែត្រលេខ៩ ហើយតំបន់ទាំង៣នោះ មានសារៈប្រយោជន៍ជាច្រើនដូចជា៖



-ជួយរំដោះទឹកតំបន់ទួលគោក ដោយបូមចេញតាមស្ថានីយ៍បឹងកក់២ ជាប់ផ្លូវរទេះភ្លើង
-តំបន់វត្តភ្នំ ស្រះចក សហគមន៍បឹងកក់ ខណ្ឌដូនពេញ ដែលត្រូវបង្ហូរចេញកាត់ផ្លូវលេខ៧០ តាមប្រអប់លូជ្រុងដែលយើងកំពុងស្តាបនានេះ
-ខណ្ឌឫស្សីកែវទាំងមូល និងមួយផ្នែកខណ្ឌសែនសុខ ត្រូវបានបង្ហូរចូលទៅក្នុងប្រឡាយចំនួន២ គឺមានប្រឡាយបាក់ទូក និងអូរវែង។

អាស្រ័យហេតុនេះ សូមបងប្អូនដែលរស់នៅ និងឆ្លងកាត់ការដ្ឋានទាំងនេះ សូមមេត្តាយោគយល់អធ្យាស្រ័យ និងសូមមេត្តាចូលរួមសហការ ជំរុញការដ្ឋាននេះ ឱ្យដំណើរការដោយជោគជ័យ។ តាមបទពិសោធន៍កន្លងមក ក្រុមហ៊ុនមួយចំនួនតូច បានចូលរួមក្នុងកិច្ចការលទ្ធកម្ម ភាគច្រើនហ៊ានដេញថ្លៃទាបខ្លាំង ប៉ុន្តែពេលអនុវត្តន៍គម្រោង មានភាពយឺតយ៉ាវ គ្មានសោភ័ណភាព គុណភាព សុវត្ថិភាព ដែលមិនអាចទទួលយកបានឡើយ៕






## ក្រុមប្រឹក្សាខណ្ឌទួលគោកបើកកិច្ចប្រជុំសាមញ្ញលើកទី១៧

កិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ក្រុមប្រឹក្សាខណ្ឌទួលគោក អាណត្តិទី២ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដែលមានរបៀបវារៈដូចខាងក្រោម៖



-ការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាង កំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី១៦ របស់ក្រុមប្រឹក្សាខណ្ឌទួលគោកអាណត្តិទី២
-ការពិនិត្យ ការពិភាក្សាសេចក្តីព្រាង របាយការណ៍លទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០១៥ របស់រដ្ឋបាលសាលាខណ្ឌទួលគោក
-ការពិនិត្យ ពិភាក្សា សេចក្តីព្រាង ដីកាស្តីពីការកំណត់តម្លៃសេវារដ្ឋបាល និងតារាងតម្លៃសេវាសាធារណៈរបស់សាលាខណ្ឌទួលគោក
-ការពិនិត្យ ពិភាក្សាអនុម័តសេចក្តីព្រាង ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តបានមកពីសេវារដ្ឋបាលប្រចាំ ខែកញ្ញា ២០១៥ ជូនមន្ត្រីរបស់រដ្ឋបាលខណ្ឌ
-ការងារផ្សេងៗ៕



## អាជ្ញាធរសង្កាត់ទឹកល្អក់ទី១ នាំអំណោយជូនអ្នករងគ្រោះ

នៅល្ងាចថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ក្រុមការងារអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌទួលគោក ដែលដឹកនាំ ដោយ **លោក សាំង សុភៈវិចិត្រ** និងមន្ត្រីកាកកបាទក្រហម ខណ្ឌរួមជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី១ និងក្រុមការងារ សសយក សង្កាត់បានចុះសួរសុខទុក្ខ៖



១. **លោកស្រី ទៀវ ហោរ** សមាជិកក្រុមប្រឹក្សាសង្កាត់ដែល កំពុងសម្រាកព្យាបាលជំងឺដោយការវះកាត់ឆ្អឹងខ្នង នៅមន្ទីរពេទ្យអង្គរធំ .
២. **លោក ណុប គា** មេភូមិ២០ ដែលរងរបួសដោយគ្រោះថ្នាក់ចរាចរណ៍បាក់ឆ្អឹងជងកាំបិត ដោយបានឧបត្ថម្ភ អង្ករ ២៥គីឡូក្រាម ទឹកដោះគោឆៅពីរឡូ និងថវិកា ៣០ម៉ឺនរៀល ក្នុងម្នាក់។ បន្ទាប់មកក៏បានបន្តសួរសុខទុក្ខលោកស្រី សយ ចន្ធី ដែលកំពុងមានជំងឺស្លាប់មួយចំហៀងខ្លួន ដោយបានឧបត្ថម្ភនូវអង្ករ២៥គីឡូក្រាម ទឹកដោះគោឆៅ២ឡូ និងថវិកា៣៩ម៉ឺនរៀល៕





# សាលាខណ្ឌដូនពេញបានរៀបចំធ្វើវេទិកាសាធារណៈមូលដ្ឋាន នៅក្នុងសង្កាត់ចតុមុខ



មន្ត្រីអាជ្ញាធរ និងប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនក្នុងពិធី

នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤ នៅសាលាមតេយ្យ ៨មីនា បានរៀបចំធ្វើវេទិកាសាធារណៈក្រោមអធិតីភាព **លោក គួច ចំរើន អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ** និង **ជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានសង្កាត់ចតុមុខ** និង **លោកជំទាវ ម៉ិញ ភុសនី អនុប្រធានទី១ ក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានសង្កាត់ចតុមុខ** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តន៍កម្មវិធីគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ។



អាជ្ញាធរមូលដ្ឋានបកស្រាយតាមការស្នើសុំរបស់ប្រជាពលរដ្ឋ

ក្នុងឱកាសនេះដែរ **លោក គួច ចំរើន អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ** និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានសង្កាត់ចតុមុខ បានផ្តាំផ្ញើទៅសង្កាត់ ប៉ុស្តិ៍ និងមន្ត្រីក្រោមឱវាទ រួមគ្នាអនុវត្ត គោលនយោបាយ ភូមិ-សង្កាត់ មានសុវត្ថិភាព ឱ្យសម្រេចបាននូវលក្ខណៈសម្បត្តិទាំង០៩យ៉ាង ហើយដោះស្រាយសំណូមពរ និង កង្វល់ផ្សេងៗ របស់បងប្អូនប្រជាពលរដ្ឋ៕







អាជ្ញាធរខណ្ឌដូនពេញចុះកាយសំរាមពេលទឹកជន់លិចទីក្រុង



## ថ្នាក់ដឹកនាំសាលាខណ្ឌដង្កោ ជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី ភូមិតាឡី សង្កាត់ដង្កោ

នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ **លោក នុត ពុធដារ៉ា អភិបាល នៃគណៈអភិបាលខណ្ឌដង្កោ** បានជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី ក្នុងភូមិថ្មី និងភូមិតាឡី សង្កាត់ដង្កោ ប្រមាណ ៣០០នាក់ អំពីបញ្ហាតម្លៃអគ្គិសនីនៅតាមបន្ទប់ជួល និងបញ្ហាប្រឈម និងតម្រូវការនានារបស់ពួកគាត់ ដោយមានការចូលរួមពីសំណាក់ **លោក សំ សឿន ប្រធានសហភាពពលកម្មជាតិកម្ពុជា** និងតំណាងសាខាអគ្គិសនីអូបែកក្អម។

ក្នុងឱកាសនេះដែរ **លោកអភិបាលខណ្ឌ** បានលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋដែលស្នាក់នៅតាមផ្ទះជួល បន្ទប់ជួលទាំងអស់ រាយការណ៍ដល់សមត្ថកិច្ច មានអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ អំពីបញ្ហាការលំបាក និងកង្វល់នានារបស់បងប្អូន ដើម្បីចាត់វិធានការដោះស្រាយជូនបានទាន់ពេលវេលា៕













## សាលាខណ្ឌពោធិ៍សែនជ័យបើកការដ្ឋានជួសជុលផ្លូវបេតុង

នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ **លោក ហែម ដារិទ្ធិ អភិបាល នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ** បានបើកការដ្ឋានជួសជុលផ្លូវបេតុងឆ្អឹងដែកចំនួន១ខ្សែប្រវែង៤៩០ម៉ែត្រ ទទឹង៥ម៉ែត្រ ដែលជាគម្រោងអភិវឌ្ឍន៍របស់ខណ្ឌឆ្នាំ២០១៥ ស្ថិតនៅភូមិព្រៃកី សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



នេះជាសមិទ្ធិផលថ្មីបន្ថែមទៀត សូមបងប្អូនប្រជាពលរដ្ឋជួយថែរក្សាទាំងអស់គ្នាឱ្យបានល្អ។

បន្ទាប់មក **លោកអភិបាលខណ្ឌ** ក៏បានឆ្លៀតចុះពិនិត្យការធ្វើអត្តសញ្ញាណប័ណ្ណជូនបងប្អូនប្រជាពលរដ្ឋ នៅសង្កាត់ភ្លើងឆេះរទេះ៕







## សាលាខណ្ឌពោធិ៍សែនជ័យចុះសាកសួរសុខទុក្ខកងទ័ព

នាថ្ងៃទី០៧-០៨ ខែតុលា ឆ្នាំ២០១៥ **លោក ហែម ដារិទ្ធិ អភិបាល នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ** បានដឹកនាំមន្ត្រីរាជការ កងកម្លាំង យុវជន ចុះសួរសុខទុក្ខ និងផ្តល់សំភារៈ ថវិកាជូនកងនគរបាលវរៈ សេនាតូច ៧៩៣ ការពារព្រំដែន ឈរជើងនៅចំណុចអានសេះ ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។



ក្នុងនោះផងដែរ ប្រតិភូក៏បាននាំយកមកនូវ អំណោយមួយចំនួនចែកជូនដល់គ្រួសារកងទ័ព ដែលក្នុងមួយគ្រួសារៗ ទទួលបានសម្ភារៈមាន មី ទឹកត្រី ទឹកស៊ីអ៊ីវ ស្ករស បន្លែ ថ្នាំពេទ្យ ព្រមទាំងថវិកាសរុប ចំនួន ២០.៩២០.០០០រៀល៕







**អាជ្ញាធរខណ្ឌច្បារអំពៅចុះចាប់ហ្គេមបាញ់ត្រីខុសច្បាប់**



**អាជ្ញាធរខណ្ឌច្បារអំពៅចុះបូមទឹក និងឈូសឆាយជង្ហុកផ្លូវ**



អនុវត្តតាមគោលការណ៍របស់ **ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល** នៃគណៈអភិបាលរាជធានីភ្នំពេញ និងការណែនាំពី លោក **អ៊ិច ស៊ីផាន អភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅ** កងកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ ដែលដឹកនាំដោយ



**លោក ហោ វាសនា អភិបាលរងខណ្ឌ** បានចុះត្រួតពិនិត្យរដ្ឋបាល នៅចំណុចផ្ទះលេខ ១៨ផ្លូវបេតុង ភូមិអូរអណ្ដូង១ សង្កាត់ព្រែកប្រា ដែលមានពាក់ព័ន្ធលើបញ្ហាគ្រឿងញៀន ជាលទ្ធផលកម្លាំងចម្រុះ បានធ្វើការពិនិត្យឃើញមានការលេងល្បែងស៊ីសង ហ្គេមបាញ់ត្រី ខុសច្បាប់ ចំនួន៣ទូ បច្ចុប្បន្នកម្លាំងចម្រុះបានរឹបអូសយកមករក្សា ទុកជាបណ្ដោះអាសន្ននៅសាលាខណ្ឌដើម្បីចាត់ការតាមនីតិវិធីច្បាប់៕

ដោយនៅក្នុងកំឡុងខែតុលា ឆ្នាំ២០១៥ មានភ្លៀងធ្លាក់ ជោកជាំបណ្ដាលអោយផ្លូវជាតិលេខ២១ ចាប់ពីភូមិក្ដីតាកុយ រហូត ដល់គល់ស្ពានព្រះមុនីវង្សមានជង្ហុកធំៗរួមទាំងទឹកដក់ធ្វើអោយបង ប្អូនប្រជាពលរដ្ឋពិបាកក្នុងការធ្វើដំណើរ ហេតុដូចនេះដើម្បីបង្ក លក្ខណៈជូនបងប្អូនប្រជាពលរដ្ឋ ដោយក្នុងនោះអាជ្ញាធរខណ្ឌច្បារ អំពៅបានទំនាក់ទំនងសុំជួយអន្តរាគមន៍ពីក្រុមការងារ JICA ដើម្បី បូមលូទឹកដក់នៅតាមផ្លូវជាតិលេខ២១ និងឈូសឆាយចាក់ថ្មគ្រួស លុបជង្ហុកធំៗ ដើម្បីសម្រួលក្នុងការធ្វើដំណើរ៕










## កិច្ចប្រជុំសាមញ្ញលើកទី១៦ របស់ក្រុមប្រឹក្សាខណ្ឌ៧មករា

នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ រដ្ឋបាលសាលាខណ្ឌ ៧មករា ប្រជុំសាមញ្ញលើកទី១៦ របស់ក្រុមប្រឹក្សាខណ្ឌ៧មករា អាណត្តិទី២ ក្រោមអធិបតីភាព **លោក សោម សុវណ្ណា ប្រធានក្រុមប្រឹក្សាខណ្ឌ៧មករា** និង **លោក លឹម សុភា អភិបាល នៃគណៈអភិបាលខណ្ឌ ៧មករា** ដែលមានរបៀបវារៈមួយចំនួនដូចខាងក្រោម៖

**១-** ឆ្លង និងអនុម័តសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី១៥ ខែសីហា របស់ក្រុមប្រឹក្សាខណ្ឌ៧មករា អាណត្តិទី២។

**២-**ពិនិត្យ និង អនុម័តសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០១៥ របស់រដ្ឋបាលខណ្ឌ៧មករា។



**៣-**ពិនិត្យ និង អនុម័តសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារត្រីមាសទី៣ ឆ្នាំ២០១៥ របស់រដ្ឋបាលខណ្ឌ៧មករា។

**៤-**អនុម័តការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ជូនមន្រ្តីរាជការ៕




សកម្មភាពពិនិត្យ និងអនុម័តរបស់ក្រុមប្រឹក្សាខណ្ឌ៧មករា




## ថ្នាក់ដឹកនាំសាលាខណ្ឌ៧មករា ចុះពិនិត្យគម្រោងដាក់លូ

នៅព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ **លោក លឹម សុភា អភិបាល នៃគណៈអភិបាលខណ្ឌ៧មករា** និងជាប្រធានគណៈកម្មាធិការលទ្ធកម្មខណ្ឌ បានចុះត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍របស់សាលាខណ្ឌ ៧មករា សម្រាប់ឆ្នាំ២០១៥ លើគម្រោងដាក់លូទំហំ០,៦ម ចំនួនពីរខ្សែ



១- ផ្លូវលេខ១៦៩ (ផ្លូវលេខ១៦៩ ដល់ផ្លូវលេខ១០៩) ប្រវែង ៥៣២ម។

២- ផ្លូវលេខ១៦៤ (ផ្លូវលេខ១៦៤ ដល់ផ្លូវលេខ១៣៤) ប្រវែង ២២០ម ក្នុងសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ៕





## ចំណេះដឹងទូទៅ៖ **ប្រវត្តិ ស្ពានជ្រោយចង្វារ**



ស្ពានជ្រោយចង្វារ ឬស្ពានមិត្តភាពកម្ពុជា-ជប៉ុន គឺជាស្ពានមួយដ៏សំខាន់សម្រាប់ការធ្វើដំណើររបស់ប្រជាពលរដ្ឋពីខេត្តសៀមរាប កំពង់ធំ កំពង់ចាម រតនៈគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង ចូលមកកាន់រាជធានីភ្នំពេញ។ ដែលស្ពាននេះត្រូវបានស្ថាបនាឡើងកាលពីឆ្នាំ១៩៦៦ នៃសម័យសង្គមរាស្ត្រនិយម **របស់សម្តេចព្រះវររាជបិតាជាតិខ្មែរ ព្រះករុណាសម្តេចព្រះនរោត្តម សីហនុ** (១៩៥៣-១៩៧០)។ ស្ពាននេះ មានប្រវែង ៧០៩ម៉ែត្រ ដែលបានតភ្ជាប់ពីត្រើយខាងលិច ទៅត្រើយខាងកើត។



ជាអកុសល ស្ពានជ្រោយចង្វារត្រូវបានកម្ទេចនៅឆ្នាំ១៩៧២ ដោយក្រុមកកុម្មង់ដូអត្តឃាតវៀតកុង ចំនួន ១០១នាក់ ដោយដាក់បង្កើគ្រាប់បែកក្នុងរថយន្តកាមីញ៉ុង។



រហូតមកដល់ឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា បានស្តារហេដ្ឋារចនាសម្ព័ន្ធនៅក្នុងរាជធានីភ្នំពេញឡើងវិញ បន្ទាប់ពីប្រទេសជាតិបានជួបប្រទះនឹងសង្គ្រាមអស់ជាច្រើនឆ្នាំ។ ជាមួយគ្នានោះដែររាជរដ្ឋាភិបាលជប៉ុន ក៏បានផ្តល់នូវអំណោយសាងសង់ឡើងវិញស្ពាននេះនាឆ្នាំ១៩៩៥នោះ។

ស្ពានជ្រោយចង្វារនេះ គឺជាស្ពានដែលវែងជាងគេដំបូងបង្អស់ នៅកម្ពុជា ដែលឆ្លងកាត់ទន្លេ ហើយវាក៏ជាស្ពានដ៏សំខាន់របស់ប្រជាពលរដ្ឋ និងទំនាក់ទំនងនៃហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា៕





# ចំណេះដឹងសុខភាព៖ **អាហារ៤ប្រភេទមិនគួរទទួលទានពេលព្រឹក! អាហារដែលមានប្រូតេអ៊ីនខ្ពស់! សារៈប្រយោជន៍ផ្លែក្រូចត្លុង និងផ្លែមង្ឃុត**

## អាហារ៤ប្រភេទមិនគួរទទួលទានពេលព្រឹក!



សម្រាប់មនុស្សភាគច្រើនជឿថា ពេលព្រឹកទទួលទានអ្វីក៏មានប្រយោជន៍ដែរ ព្រោះរាងកាយ ត្រូវយកទៅចិញ្ចឹមខួរក្បាល ប៉ុន្តែអាហារ៤យ៉ាងដែលគួរចៀសវាងគឺ៖

**នំប៉័ងលាបសូកូឡា** ប្រសិនបើទទួលទានហើយនំប៉័ងលាបសូកូឡា អ្នកមានអារម្មណ៍ស្កុះស្កាល្អ គឺបណ្ដាលមកពីជាតិស្ករនៅក្នុងសូកូឡា។ គួរលាបប៊ឺសណ្ដែក ឬដំណាប់ផ្លែឈើប្រសើរជាង។

**អាហារធញ្ញជាតិ** ការស្រាវជ្រាវពីអាហារបានរកឃើញថា ជិត១០០ភាគរយនៃផលិតផលអាហារធញ្ញជាតិត្រូវបានផលិតឡើងតាមរយៈយន្តការបំប្លែងតំណពូជពីសណ្ដែកសៀង(GMO Material) មិនមែនផលិតមកពីធញ្ញជាតិគ្រាប់ពេញ(Whole Grain)សុទ្ធ១០០ភាគរយដូចដែលបញ្ជាក់នៅក្នុងស្លាកផលិតផលនោះទេ។ ដូច្នេះប្រយោជន៍ដែលរាងកាយអាចយកទៅប្រើការបានពិតប្រាកដគឺមានតែទឹកដោះគោតែមួយមុខគត់។

**នំធញ្ញជាតិ** ដែលអ្នកមើលឃើញថាពោរពេញទៅដោយធញ្ញជាតិ ប៉ុន្តែអាហារប្រភេទនេះមានសមាសធាតុផ្សំនៃជាតិស្ករយ៉ាងតិច៣ប្រភេទឡើងទៅដូចជាស្ករហ្វ្រុកតូស(Fructose) ទឹកស្ករពោត(HighFructose Corn Syrup)ស្ករក្រហមនិងស្ករអំពៅ។ ដូច្នេះប្រសិនបើអ្នកជ្រើសនំធញ្ញជាតិបែបនេះមកទទួលទានជាអាហារពេលព្រឹកស្មើនឹងយកជាតិស្ករ ដាក់ចូលក្នុងមាត់ប្រមាណ៣០ក្រាមទោះជារសជាតិមិនដូចស្ករក្ដី។

**សាច់កែច្នៃ** ជាអាហារពេលព្រឹកដែលអ្នកគួរទទួលទានឱ្យតិចបំផុត។ ទិន្នន័យដែលទទួលបានពីសាលាវេជ្ជសាស្ត្រហាវ៉ាដ(Harvard Medicine School)បង្ហាញនូវលទ្ធផលការស្រាវជ្រាវថា ប្រសិនបើផ្អាកបរិភោគផលិតផលសាច់កែច្នៃ១០០ក្រាមក្នុង១ថ្ងៃអាចជួយបន្ថយអត្រាប្រឈមនឹងការបាត់បង់ជីវិតមុនវ័យដល់២០ភាគ៕

## ប្រភេទអាហារដែលមានផ្ទុកសារជាតិប្រូតេអ៊ីនខ្ពស់

អ្នកគួរធ្វើការទទួលទានសារជាតិប្រូតេអ៊ីនឱ្យបានយ៉ាងតិច ៥០ក្រាមក្នុងមួយថ្ងៃ។ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ពេញលេញរបស់វា។ ប្រភេទអាហារដែលសំបូរទៅដោយសារជាតិប្រូតេអ៊ីន គឺមានមកពីសត្វមានដូចជា ទឹកដោះគោ ស៊ុត និងសាច់។

ប្រភេទអាហារដែលមានផ្ទុកសារជាតិប្រូតេអ៊ីន ក្នុងបរិមាណខ្ពស់ គឺមានសារៈប្រយោជន៍ក្នុងការរក្សាខ្លួនអ្នកឲ្យមានថាមពល និងធ្វើឲ្យមុខងាររបស់រាងកាយអ្នកមានដំណើរការបានល្អ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកធ្វើការជ្រើសរើសបរិភោគតែបន្លែ និង ផ្លែឈើ នោះអ្នកអាចបរិភោគនូវសណ្ដែកខៀវមួយពែងកន្លះ ដែលវាអាចនឹងមានជាតិប្រូតេអ៊ីនស្មើនឹងបន្ទះសាច់ចៀន ១០០ក្រាម។




ប្រភេទអាហារដែលមានផ្ទុកជាតិប្រូតេអ៊ីន គឺអាចជួយធ្វើឱ្យអ្នកមានអារម្មណ៍ថាឆ្អែតបន្ទាប់ពីទទួលទានអាហាររួច មានថាមពលពេញមួយថ្ងៃ ហើយវាក៏ផ្ដល់អត្ថប្រយោជន៍ផងដែរដល់សាច់ដុំ ការរីកធំធាត់ និងសុខុមាលភាពទាំងស្រុងរបស់រាងកាយ។

ប្រភេទអាហារដែលសំបូរទៅដោយសារជាតិប្រូតេអ៊ីន មានសណ្ដែកខៀវ ស៊ុត ផលិតផលធ្វើពីជាតិទឹកដោះគោ អាហារសមុទ្រ សាច់បក្សី សណ្ដែកសៀង សាច់គោ។ ប្រសិនបើអ្នកបានបរិភោគនូវអាហារ ដែលមានផ្ទុកនូវសារជាតិប្រូតេអ៊ីនបន្តិច នោះអ្នកនឹងមានអារម្មណ៍ថា មិនសូវឃ្លាននៅក្នុងពេលថ្ងៃ និងមិនសូវមានចំណង់ញ៉ាំច្រើន ឬចង់ទទួលទានអាហារសម្រន់ច្រើននោះទេ៕

## ក្រូចត្លុងមានសារៈប្រយោជន៍ចំពោះសុខភាព!




អ្នកចូលចិត្តបរិភោគក្រូចត្លុង ដោយសារវាល្អសម្រាប់ការរំលាយអាហារផង និងជួយបញ្ចុះទម្ងន់ ដូច្នេះក្រូចត្លុងអាចព្យាបាលជំងឺគ្រុនក្តៅ និងជំងឺផ្តាសាយ ទឹកក្រូចត្លុង ជួយអ្នកជំងឺឱ្យមានសុខភាពល្អឡើងវិញក្រោយជំងឺគ្រុនក្តៅ បន្ថយអារម្មណ៍ក្តៅរោលរាល ដោយសារសីតុណ្ហភាពសរីរាង្គឡើងខ្ពស់ និងជាឱសថមានតម្លៃចំពោះជំងឺគ្រុនផ្តាសាយ ។

**ក្រូចត្លុង**មានប្រយោជន៍បំផុតក្នុងការដោះស្រាយបញ្ហាហើមពោះ ពិបាករំលាយអាហារវាធ្វើឱ្យថយចុះកម្តៅ និងរំញោចសកម្មភាពរបស់ក្រពះ កែប្រែឱ្យប្រសើរចរន្តហូររបស់រំអឹលរំលាយអាហារ ជួយសរីរាង្គរំលាយអាហារល្អជាង ។

សម្រាប់អ្នកជំងឺទឹកនោមផ្អែម គួរបរិភោគក្រូចត្លុងមួយផ្លែក្នុងមួយថ្ងៃ វាអាចរារាំងបរិមាណម្សៅបញ្ចូលទៅក្នុងសរីរាង្គ ហេតុនេះជួយបន្ថយក្តីបារម្ភអំពីជំងឺទឹកនោមផ្អែម។ ផឹកទឹកក្រូចត្លុងស្រស់មួយកែវនៅពេលព្រឹកល្អបំផុតដើម្បីគ្រប់គ្រងអាការៈទល់លាមក ។

ការផឹកទឹកក្រូចត្លុង៥៣០មិល្លីលីត្រក្នុងមួយថ្ងៃ នឹងធ្វើឱ្យសកម្មភាពរបស់ CYPIA2 ដែលជាអង់ហ្ស៊ីមមួយរំញោចសកម្មភាពរបស់សារជាតិគីមី បង្កជំងឺមហារីកក្នុងផ្សែងបារីថយចុះគួរឱ្យកត់សម្គាល់។ ក្រៅពីនេះ ក្រូចត្លុង សម្បូរសារជាតិ flavonoid មានឥទ្ធិពលដូចជាសារជាតិប្រឆាំងអុកស៊ីតកម្ម ធម្មជាតិ១ ការពារនិងទប់ស្កាត់សកម្មភាពរបស់ពពួកសារជាតិបង្កមហារីក៕




## ផ្លែមង្ឃុតជួយការពារជំងឺបេះដូង និងសម្ពាធឈាម



ពិតណាស់ការពិសាអាហារដែលមានតុល្យភាពល្អ នឹងជួបបង្កើតនូវសុខភាពល្អរបស់ មនុស្សគ្រប់ៗរូប។ ផ្លែឈើ គឺជាចំណែកមួយនៃតុល្យភាពចំណីអាហារ។ ជាទូទៅរាល់ការពិសាផ្លែឈើត្រឹមត្រូវរួមមានផ្លែមង្ឃុតនេះគឺអាចធ្វើ ឱ្យសុខភាពនិងគុណភាពនៃជីវិតរបស់លោកអ្នកមានការខុសប្លែកគ្នាគួរឱ្យ កត់សម្គាល់។



**ផ្លែមង្ឃុត** ជាផ្លែឈើដែលដុះលូតលាស់នៅតំបន់អាស៊ីអាគ្នេយ៍។ ដើមមង្ឃុតអាចរស់រានបានល្អនៅក្រោមសីតុណ្ហភាព៤០ អង្សា និងមានភ្លៀងធ្លាក់គ្រប់គ្រាន់ ផ្លែមង្ឃុតអាចជួយការពារជំងឺបេះដូង និងសម្ពាធឈាមឲ្យដំណើរការបានល្អ៕



# ព្រំប្រទល់រដ្ឋបាល រាជធានីភ្នំពេញ




- ផ្ទៃដីសរុប = ៦៧.៨០០ ហ.ត
- ប្រជាជន = ១.៥០១.៧២៥
- ចំនួនគ្រួសារ = ២៩៥.៣៥៨
- ដង់ស៊ីតេ (ន/ហ.ត) = ១.១៥៩
- ខណ្ឌ = ១២
- សង្កាត់ = ៩៦
- ភូមិ = ៩០៩